KRESTON
CAMBODIA



# Instructions on strengthening the implementation of normal invoice

# (Commercial Invoice)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៣៣៣០៤ អពដ

L202308140536TD3986

ថ្ងៃ ចន្ទ ៤ កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០២៣

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹងការអនុវត្តវិធាននៃការប្រើប្រាស់វិក្កយបត្រធម្មតា (Commercial Invoice)

អនុលោមតាមមាត្រា៧៨ និងមាត្រា៧៩ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ និងប្រកាសលេខ ៧២៣ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ស្តីពីវិធាននៃការប្រើប្រាស់វិក្កយបត្រ អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ត្រូវចេញវិក្កយបត្រអាករ (Tax Invoice) ទៅឱ្យអ្នកទិញដែលជាអ្នកជាប់ពន្ធស្ថិតនៅក្រោមរបបស្វ័យប្រកាស និងត្រូវចេញវិក្កយបត្រធម្មតា (Commercial Invoice) ទៅឱ្យអ្នកទិញដែលមិនស្ថិតនៅក្រោមរបបស្វ័យប្រកាស។ ដោយឡែក ចំពោះអ្នកជាប់ពន្ធតូច ត្រូវចេញវិក្កយបត្រធម្មតា (Commercial Invoice) ទៅឱ្យអ្នកទិញទាំងអស់ ទោះបីជាអ្នកទិញទាំងអស់នោះជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬមិនស្ថិតនៅក្រោមរបបស្វ័យប្រកាសដែលជាអ្នកប្រើប្រាស់ចុងក្រោយក៏ដោយ។

កន្លងមក អគ្គនាយកដ្ឋានពន្ធដារ បានកត់សម្គាល់ឃើញថា សហគ្រាសភាគច្រើនបានអនុវត្តការចេញវិក្កយបត្រធម្មតាទៅឱ្យអ្នកប្រើប្រាស់ចុងក្រោយបានត្រឹមត្រូវ ស្របតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ប៉ុន្តែមានសហគ្រាសមួយចំនួនដែលមានសកម្មភាពអាជីវកម្មផ្គត់ផ្គង់ទំនិញ ដែលមានលក្ខណៈជាការលក់រាយច្រើនមុខនូវទំនិញមានតម្លៃទាប និងមានប្រតិបត្តិការច្រើនប្រចាំថ្ងៃ មិនទាន់អនុវត្តបានត្រឹមត្រូវនៅឡើយ ជាពិសេសសហគ្រាសប្រកបអាជីវកម្មហាងទំនិញលក់រាយ និងស្ថានីយប្រេងឥន្ធនៈឬឧស្ម័នហ្គាស។

ក្នុងគោលបំណងពង្រឹងការអនុវត្តវិធាននៃការប្រើប្រាស់វិក្កយបត្រធម្មតាឱ្យមានសង្គតិភាព ស័ក្តិសិទ្ធិភាព និងត្រឹមត្រូវស្របច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំបន្ថែមអំពីវិធាននៃការប្រើប្រាស់វិក្កយបត្រធម្មតា សម្រាប់សហគ្រាសប្រកបអាជីវកម្មហាងទំនិញលក់រាយ និងស្ថានីយប្រេងឥន្ធនៈឬឧស្ម័នហ្គាស ចំពោះការផ្គត់ផ្គង់ទៅឱ្យអ្នកប្រើប្រាស់ចុងក្រោយ ដូចខាងក្រោម៖

### ១. សហគ្រាសប្រកបអាជីវកម្មហាងទំនិញលក់រាយ

ក- រាល់ប្រតិបត្តិការផ្គត់ផ្គង់នីមួយៗ សហគ្រាសត្រូវចេញវិក្កយបត្រធម្មតា ទោះបីជាការចេញវិក្កយបត្រសរសេរដោយដៃ ឬម៉ាស៊ីនគិតលុយតាមប្រព័ន្ធ POS ឬតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត និងត្រូវប្រើទម្រង់ជាវិក្កយបត្រដែលមានលេខរៀងវិក្កយបត្រ និងមាននិទ្ទេសសំខាន់ៗ ស្របតាមវិធាននៃការប្រើប្រាស់វិក្កយបត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ដូចមានក្នុងឧបសម្ព័ន្ធ១ ភ្ជាប់មកជាមួយ។

ខ- សហគ្រាសត្រូវរៀបចំប័ណ្ណទទួលចំណូល (Receipt Voucher) សរុបប្រចាំថ្ងៃ ដោយបូកសរុបវិក្កយបត្រដែលបានចេញប្រចាំថ្ងៃ (សម្រាប់ប្រើប្រាស់ផ្ទៃក្នុង)។ ក្នុងករណីសហគ្រាសប្រើប្រាស់ម៉ាស៊ីនគិតលុយតាមប្រព័ន្ធ POS ឬតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀតលើសពីមួយ សហគ្រាសត្រូវរៀបចំប័ណ្ណទទួលចំណូល (Receipt Voucher) ទៅតាមប្រព័ន្ធ POS ឬតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត នីមួយៗដាច់ដោយឡែកពីគ្នា។ ទម្រង់ប័ណ្ណទទួលចំណូលប្រចាំថ្ងៃ ត្រូវមានកាលបរិច្ឆេទ និងលេខរៀងជាលំដាប់ពេញមួយឆ្នាំ ដោយត្រូវមានព័ត៌មានលម្អិតនូវលេខសម្គាល់ម៉ាស៊ីនគិតលុយ

L202308140536TD3986

ចំនួនវិក្កយបត្រប្រចាំថ្ងៃដែលបានចេញ (លេខរៀងចាប់ផ្ដើម និងលេខរៀងចុងក្រោយប្រចាំថ្ងៃ) និងចំនួនទឹកប្រាក់សរុប ដូចមានក្នុងឧបសម្ព័ន្ធ២ ភ្ជាប់មកជាមួយ។

គ- សម្រាប់គោលដៅនៃការប្រកាសពន្ធប្រចាំខែ ត្រូវបានអនុញ្ញាតឱ្យប្រកាសចំណូលពីប្រតិបត្តិការលក់តាមលេខប័ណ្ណទទួលចំណូលប្រចាំថ្ងៃនីមួយៗ ដោយបញ្ចូលព័ត៌មានក្នុងប្រអប់បរិយាយនៃប្រព័ន្ធប្រកាសពន្ធអាជីវកម្មប្រចាំខែតាមអនឡាញ (e-Filing) នូវលេខរៀងវិក្កយបត្រប្រចាំថ្ងៃ (លេខរៀងចាប់ផ្ដើម និងលេខរៀងចុងក្រោយប្រចាំថ្ងៃ) និងលេខម៉ាស៊ីនគិតលុយ (ក្នុងករណីចេញវិក្កយបត្រតាមម៉ាស៊ីនគិតលុយ)។ ទន្ទឹមនេះ សហគ្រាសត្រូវមានឯកសារភ័ស្តុតាងទាក់ទិននឹងប្រតិបត្តិការលក់ ដែលអាចត្រួតពិនិត្យបានសម្រាប់គោលដៅពន្ធដារ។

២. សហគ្រាសប្រកបអាជីវកម្មស្ថានីយប្រេងឥន្ធនៈ ឬឧស្ម័នហ្គាស

ក- រាល់ប្រតិបត្តិការផ្គត់ផ្គង់នីមួយៗ សហគ្រាសត្រូវចេញវិក្កយបត្រធម្មតា ទោះបីជាការចេញវិក្កយបត្រសរសេរដោយដៃ ឬម៉ាស៊ីនគិតលុយតាមប្រព័ន្ធអេឡិចត្រូនិក និងត្រូវប្រើទម្រង់ជាវិក្កយបត្រដែលមានលេខរៀងវិក្កយបត្រ និងមាននិទ្ទេសសំខាន់ៗ ស្របតាមវិធាននៃការប្រើប្រាស់វិក្កយបត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ដូចមានក្នុងឧបសម្ព័ន្ធ១ ភ្ជាប់មកជាមួយ។

ខ- សហគ្រាសត្រូវរៀបចំប័ណ្ណទទួលចំណូល (Receipt Voucher) សរុបប្រចាំថ្ងៃ ដោយបូកសរុបវិក្កយបត្រដែលបានចេញប្រចាំថ្ងៃ ទៅតាមទូឬម៉ាស៊ីនចាក់សាំងនៃស្ថានីយនីមួយៗដាច់ដោយឡែកពីគ្នា។ ក្នុងករណីសហគ្រាសចេញវិក្កយបត្រតាមម៉ាស៊ីនគិតលុយរួមតែមួយ ត្រូវរៀបចំប័ណ្ណទទួលចំណូល (Receipt Voucher) សរុបប្រចាំថ្ងៃរួមតែមួយ។ ទម្រង់ប័ណ្ណទទួលចំណូលសរុបប្រចាំថ្ងៃត្រូវមានការិយបរិច្ឆេទ និងលេខរៀងជាលំដាប់ពេញមួយឆ្នាំ ដោយត្រូវមានព័ត៌មានលម្អិតនូវចំនួនវិក្កយបត្រប្រចាំថ្ងៃដែលបានចេញ (លេខរៀងចាប់ផ្ដើម និងលេខរៀងចុងក្រោយប្រចាំថ្ងៃ) លេខសម្គាល់ទូឬម៉ាស៊ីនចាក់សាំង លេខកុងទ័រ (លេខចាប់ផ្ដើម និងលេខចុងក្រោយប្រចាំថ្ងៃ) និងចំនួនទឹកប្រាក់សរុប ដូចមានក្នុងឧបសម្ព័ន្ធ៣ ភ្ជាប់មកជាមួយ។

គ- សម្រាប់គោលដៅនៃការប្រកាសពន្ធប្រចាំខែ ត្រូវបានអនុញ្ញាតឱ្យប្រកាសចំណូលពីប្រតិបត្តិការលក់តាមលេខប័ណ្ណទទួលចំណូលសរុបប្រចាំថ្ងៃនីមួយៗ ដោយបញ្ចូលព័ត៌មានក្នុងប្រអប់បរិយាយនៃប្រព័ន្ធ e-Filing នូវលេខរៀងវិក្កយបត្រប្រចាំថ្ងៃ (លេខរៀងចាប់ផ្ដើម និងលេខរៀងចុងក្រោយប្រចាំថ្ងៃ) និងលេខទូឬម៉ាស៊ីនចាក់សាំង។ ទន្ទឹមនេះ សហគ្រាសត្រូវមានឯកសារភ័ស្តុតាងទាក់ទិននឹងប្រតិបត្តិការលក់ដែលអាចត្រួតពិនិត្យបាន សម្រាប់គោលដៅពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ដែលធ្វើសកម្មភាពអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**